ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| | |
|---|---|
| សាលាឧទ្ធរណ៍ | |
| សភាព្រហ្មទណ្ឌ | |
| សំណុំរឿងព្រហ្មទណ្ឌ | |
| លេខ : ៦៣៦ | |
| ចុះថ្ងៃទី : ១៥-១១-០៤ | |
| សាលដីកា | |
| លេខ : ១៤៨ "ខ" | |
| ចុះថ្ងៃទី : ២០-១២-០៧ | |

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ដោយមានសមាសភាពដូចខាងក្រោម

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦៣៦ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ រវាង

១. ជនជាប់ចោទឈ្មោះ [redacted] សៅវង្ស ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងចំលាក់ កើតនៅភូមិស្វាយចាន់ ឃុំស្វាយស្ដូង ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ទីលំនៅមុនចាប់ខ្លួន [redacted]ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៤ បច្ចុប្បន្ននៅក្នុងឃុំ ។

២. ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារី ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កើតនៅភូមិពោធិ៍វង្ស ឃុំផ្សារក្រោម ស្រុកបាកាន ខេត្តពោធិ៍សាត់ ទីលំនៅមុនចាប់ខ្លួន [redacted] ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុន ធ្លាប់ជាប់គុកម្ដង ០៧ខែ ពីបទចោរកម្ម ចាប់ខ្លួនថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៤ បច្ចុប្បន្ននៅក្នុងឃុំ ។

៣. ជនជាប់ចោទឈ្មោះ [redacted] សុខមករា ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិកសិលានិធិ កើតនៅភូមិបំណក់ ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ទីលំនៅមុនចាប់ខ្លួន[redacted] ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៤ បច្ចុប្បន្ននៅក្នុងឃុំ ។

៤. ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ ភ្នាក់ងាររដ្ឋការសិលានិធិ កើតនៅភូមិផ្សារលើ ឃុំផ្សារលើ ស្រុកបាកាន ខេត្តពោធិ៍សាត់ ទីលំនៅមុនចាប់ខ្លួន [redacted]

ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៤ បច្ចុប្បន្ននៅក្នុងឃុំ ។

- មេធាវីឈ្មោះ [redacted] វណ្ណា និង ឈ្មោះ [redacted] សុខឃាង ។

- ត្រូវជាប់ចោទពីបទ : " ឃាតកម្មគិតទុកជាមុន " ប្រព្រឹត្តនៅភូមិពាលញែករ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធានអង្គការសិលានិធិតំណាងក្រុមហ៊ុនសិលានិធិលីមីតធីត ខេត្តពោធិ៍សាត់ ទីលំនៅភូមិក្បាលហុង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] ផល្លី ជាតំណាងក្រុមហ៊ុន សុំប្តឹងឧទ្ធរណ៍នឹងដីកាលើកលែងចោទប្រកាន់ឈ្មោះ [redacted] សុខា ។

- តាមបណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារី និង បណ្តឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] សារ៉ាត ជាព្រះរាជអាជ្ញា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចទាំងមូល ។

## ដំណើររឿងមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] ផល្លី តំណាងក្រុមហ៊ុនសិលានិធិ បានប្តឹងថា កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ ម៉ោង ០៧ល្ងាច មានចោរប្លន់សំលាប់អ្នកយាមឈ្មោះ [redacted] សោភណ្ឌ័ ភេទប្រុស អាយុ ៣២ ឆ្នាំ នៅភូមិបឹងយា ឃុំវាល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។ ចោរមិនស្គាល់មុខយកអស់ :

- លុយ ៧៦ ៥២៣ ០០០រៀល
- លុយ ៤ ១៥៤ ដុល្លារ
- ម៉ូតូ ០៣គ្រឿង ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ

១. ផ្តន្ទាទោសតម្រូវអោយធ្វើការលើឈ្មោះ [redacted] សារ៉េង្ស អាយុ ២២ឆ្នាំ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន និង ឈ្មោះ [redacted] ប៊ុណ្ណារី អាយុ ៤៤ឆ្នាំ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារ ១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិពាលញែករ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ ។ តាមមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់នៃបទឧក្រិដ្ឋ ។

២. ឱ្យរួចផុតពីបទចោទឈ្មោះ [redacted] សុខេមរា ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិពាលញែករ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ ។ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

៣. វត្ថុតាង ប្រាក់ ២២ ៧០០ ០០០៛ (ម្ភៃពីរលានប្រាំពីរសែនរៀល) និង ម៉ូតូ ០៣ គ្រឿង ត្រូវប្រគល់អោយអង្គការសិលានិធិជាម្ចាស់កម្មសិទ្ធិវិញ ៕

- ខ្សែនីឡុង ០១ខ្សែ ០៧ម៉ែត្រ
- ស្តុតពណ៌ទឹកដោះគោ ០១ដុំ
- កំប៉ុងទឹកក្រូចកូកាកូឡា

ត្រូវរិបអូស និង បំផ្លាញចោល ។

៤. សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី កំបាំងមុខជនជាប់ចោ[redacted]ុខេមរា ។ ទុកសិទ្ធិប្តឹងទាស់ និង បើកផ្លូវឧទ្ធរណ៍ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted]ផល្លី ជាតំណាងក្រុមហ៊ុន ស៊ីប្តឹងឧទ្ធរណ៍នឹង ដីកាលើកលែងចោទប្រកាន់ឈ្មោះ [redacted] សុខា ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ជនជាប់ចោទឈ្មោះ [redacted] ប៉ុណ្ណារី និង បណ្តឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] ជាព្រះរាជអាជ្ញា ប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចទាំងមូល ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍

- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍

## ដំណើរសវនាការ

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុជូនអង្គសវនាការ

ប្រធានក្រុមប្រឹក្សាអោយក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយនៅសាលាដំបូងខេត្តពោធិ៍សាត់ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តពោធិ៍សាត់ និង បណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] ប៉ុណ្ណារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ របស់តុលាការខេត្តពោធិ៍សាត់ ទុកជាបានការដដែល និង ចោទប្រកាន់លើឈ្មោះ [redacted] សុខា និង [redacted] សុខេមរា ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្នុងរឿងនេះកូនក្តីខ្លួនបានសារភាពថា បានប្រព្រឹត្តអំពើប្លន់មែន តែមិនបានមានបំណងសំលាប់ជនរងគ្រោះទេ ដូច្នេះខ្លួនសូមសន្និដ្ឋានថា ៖ សុំលោកប្រធានមេត្តាធ្វើការកែប្រែបទ ពីបទមនុស្សឃាតគិតទុកជាមុន មកជាមនុស្សឃាតដោយអចេតនាវិញ ។

- ក្រោយពីបានស្តាប់អំនានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំនានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ៙

- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

<u>**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា**</u>

១. បណ្ដឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តពោធិ៍សាត់ និង បណ្ដឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] បុណ្ណារី ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២. ជនជាប់ចោទឈ្មោះ [redacted] សាវង្ស បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្លន់ និង សម្លាប់ជនរងគ្រោះឈ្មោះ [redacted] សោភណ័ ជាអ្នកយាមក្រុមហ៊ុនមែន ហើយថាខ្លួនមិនបានរៀបចំគំរោងទេ តែបានបញ្ជាក់ថា នៅថ្ងៃកើតហេតុវេលាល្ងាច ខ្លួនទៅលេងក្រុមហ៊ុន ជជែកលេងជាមួយឈ្មោះ [redacted] សោភណ័ និង [redacted] មូនិកា ។ លុះម៉ោង ៥ល្ងាច ឈ្មោះ [redacted] មូនិកា ដាក់លុយចូលទូរដែករួច ក៏ចេញទៅបាត់ ខ្លួនក៏ទៅទិញពោះគោទឹកប្រហុក ទឹកក្រូចកូកាដាក់ថ្នាំជាស្រេច ហើយផឹកស៊ីជាមួយ [redacted] សោភណ័ តែពីរនាក់លុះ [redacted] សោភណ័ ទន់ដៃទន់ជើង ខ្លួនក៏ហៅ [redacted] បុណ្ណារី មកលួចយកទ្រព្យក្រុមហ៊ុនសិលាមូលនិធិ ។ ពួកខ្លួនចងដៃជើងជនរងគ្រោះកំពុងសន្លប់ [redacted] បុណ្ណារី យកស្កុតបិទមាត់ ខ្លួនអូសជនរងគ្រោះដាក់ទៅម្ខាង ។ ក្រោយពីយកបានប្រាក់ និង ម៉ូតូហើយ ឮ [redacted] សោភណ័ ស្រែកអោយជួយ ខ្លួនក៏ចូលទៅវៃកសម្លាប់តែម្តង ។

ឯជនជាប់ចោទឈ្មោះ [redacted] បុណ្ណារី ក៏បានឆ្លើយសារភាពថា ខ្លួនពិតជាបានរួមធ្វើសកម្មនៅពេលប្លន់សម្លាប់នោះដែរ និងបានបញ្ជាក់ថា [redacted] សាវង្ស បបួលខ្លួនប្លន់ ខ្លួនជាអ្នកដាក់ថ្នាំក្នុងកំប៉ុងទឹកក្រូច ។

៣. តាមចម្លើយជនជាប់ចោទ [redacted] សាវង្ស ថាខ្លួនបានឆ្លើយដាក់ឈ្មោះ [redacted] សុខេមរា តែតាមពិតឈ្មោះនេះពុំបានចូលរួមធ្វើសកម្មភាពជាមួយខ្លួនទេ ។

៤. មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] សាវង្ស និង [redacted] បុណ្ណារី ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិពាលញែក ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសមានចែង និងឱ្យផ្ដន្ទាទោស តាមមាត្រា ០៣ នៃច្បាប់ស្ដីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ, តែគ្មានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] សុខេមរា ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិពាលញែក ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសមានចែង និង ឱ្យផ្ដន្ទាទោស តាមមាត្រា ០៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនោះទេ ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ របស់តុលាការខេត្តពោធិ៍សាត់ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

<u>**ហេតុដូច្នេះ**</u>

<u>**វិនិច្ឆ័យសេចក្ដី**</u>

១. ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តពោធិ៍សាត់ និង បណ្ដឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] បុណ្ណារី ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផុតនីងគតិច្បាប់ ។ ៚

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ របស់តុលាការខេត្តពោធិ៍សាត់ ឱ្យនៅជាអានុភាព ពេញទាំងមូល ។

៣. សម្រេចឃុំខ្លួនជនជាប់ចោទបន្តទៀត

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខដើមបណ្តឹង ប្រកាសជាសាធារណៈនៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ កំបាំងមុខជនជាប់ចោទ ចំពោះមេធាវីការពារជនជាប់ចោទ តែទុកជាចំពោះមុខ កំបាំងមុខដើមបណ្តឹង បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់ទីកន្លែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]